


**Are You Protected?**

Measles cases are occurring across the US and internationally. Getting the MMR vaccine is the best way to protect yourself and your family from getting measles. Staying updated with vaccines also protects those too young to be vaccinated. Learn more at: ph.lacounty.gov/measles.

**តើអ្នកមានប្រព័ន្ធការពារ ដែរឬទេ?**

ករណីនៃជំងឺកញ្ជ្រឹលគឺកំពុងកើតមានឡើងនៅទូទាំងសហរដ្ឋអាមេរិក និងប្រទេសផ្សេងទៀត។ ការទទួលចាក់ថ្នាំបង្ការ MMR គឺជាវិធីល្អបំផុតដើម្បីការពារខ្លួនអ្នកផ្ទាល់ ហើយនិងក្រុមគ្រួសាររបស់អ្នកពីការឆ្លងជំងឺកញ្ជ្រឹល។ ការទទួលចាក់ថ្នាំបង្ការថ្មីៗបំផុតក៏ការពារដល់កុមារនៅក្មេងពេកដែលមិនទាន់អាចចាក់ថ្នាំបង្ការបានផងដែរ។ ស្វែងយល់បន្ថែមនៅលើគេហទំព័រ៖ ph.lacounty.gov/measles។

**Highly Contagious**

Measles is highly contagious and can spread easily. Most people who have not been immunized against measles will get it if they have contact with the virus. Getting vaccinated is the best way to protect yourself and your family. Learn more at: ph.lacounty.gov/measles.

**ងាយស្រួលនឹងឆ្លងយ៉ាងខ្លាំង**

ជំងឺកញ្ជ្រឹលគឺងាយស្រួលនឹងឆ្លងយ៉ាងខ្លាំង ហើយអាចរីករាលដាលបានដោយមិនពិបាកនោះទេ។ មនុស្សភាគច្រើនដែលមិនទាន់បានទទួលចាក់ថ្នាំបង្ការប្រឆាំងនឹងជំងឺកញ្ជ្រឹលទេនោះនឹងឆ្លងជំងឺ ប្រសិនបើពួកគេប៉ះពាល់ទៅនឹងមេរោគជំងឺនេះ។ ការទទួលចាក់ថ្នាំបង្ការគឺជាវិធីល្អបំផុតដើម្បីការពារខ្លួនអ្នកផ្ទាល់ និងក្រុមគ្រួសាររបស់អ្នក។ ស្វែងយល់បន្ថែមនៅលើគេហទំព័រ៖ ph.lacounty.gov/measles។

**Get Immunized**

The measles-mumps-rubella (MMR) vaccine is safe and more than 95% effective in preventing measles. Review your immunization record and make sure you are protected against measles. Learn more at: ph.lacounty.gov/measles.

**ទទួលចាក់ថ្នាំបង្ការ**

ថ្នាំបង្ការសម្រាប់ជំងឺកញ្ជ្រឹល-ជំងឺស្រឡទែន-ជំងឺស្អូច (measles-mumps-rubella/MMR) គឺមានសុវត្ថិភាព ហើយមានប្រសិទ្ធិភាពច្រើនជាង 95% ក្នុងការទប់ស្កាត់មិនឱ្យឆ្លងជំងឺកញ្ជ្រឹល។ ចូរពិនិត្យមើលកំណត់ត្រានៃការចាក់ថ្នាំបង្ការរបស់អ្នកឡើងវិញ

ហើយនិងធ្វើឱ្យប្រាកដថាអ្នកមានប្រព័ន្ធការពារប្រឆាំងនឹងជំងឺកញ្ជ្រឹល។ ស្វែងយល់បន្ថែមនៅលើគេហទំព័រ៖ ph.lacounty.gov/measles។

## Know the Symptoms

Knowing the symptoms of measles is crucial for early detection. Look out for:

- 🤒 Fever
- 🔴 Rash
- 😮 Cough
- 🤧 Runny nose
- 😢 Red, watery eyes

📞 If you have symptoms or have been exposed to measles, call your doctor before going in. To learn more about measles visit: ph.lacounty.gov/measles.

## ស្គាល់អំពីរោគសញ្ញានានា

ការស្គាល់អំពីរោគសញ្ញានានានៃជំងឺកញ្ជ្រឹលគឺសំខាន់ណាស់សម្រាប់ការស្វែងរកជំងឺឱ្យបានលឿន។ សូមប្រយ័ត្នចំពោះ៖

- 🤒 គ្រុនក្តៅ
- 🔴 កន្ទួលរមាស់
- 😮 ក្អក
- 🤧 ហៀរសំបោរ
- 😢 ភ្នែកឡើងក្រហម និងហៀរទឹកភ្នែក

📞 ប្រសិនបើអ្នកមានរោគសញ្ញានានា ឬបានប៉ះពាល់ទៅនឹងជំងឺកញ្ជ្រឹល ចូរទាក់ទងទៅកាន់គ្រូពេទ្យរបស់អ្នកមុនពេលអ្នកធ្វើដំណើរទៅជួបពួកគេ។ ដើម្បីស្វែងយល់បន្ថែមអំពីជំងឺកញ្ជ្រឹល សូមចូលទៅកាន់គេហទំព័រ៖ ph.lacounty.gov/measles។

## Measles Stats

Measles is not just a childhood illness—it's a serious disease that can lead to severe complications, especially for children. Getting immunized against measles is the best way to protect yourself and others. Learn more at: ph.lacounty.gov/measles.

## ស្ថិតិជំងឺកញ្ជ្រឹល។

កញ្ជ្រឹលគឺមិនមែនជាជំងឺដែលត្រឹមតែកើតមាននាពេលកុមារភាពនោះទេ។ នេះគឺជាជំងឺមានសភាពធ្ងន់ធ្ងរមួយប្រភេទដែលអាចនាំឱ្យមានផលវិបាកកម្រិតធ្ងន់ធ្ងរផ្សេងៗ ជាពិសេសសម្រាប់កុមារ។ ការទទួលចាក់ថ្នាំបង្ការប្រឆាំងនឹងជំងឺកញ្ជ្រឹលគឺជាវិធីល្អបំផុតដើម្បីការពារខ្លួនអ្នកផ្ទាល់ និងមនុស្សផ្សេងទៀត។ ស្វែងយល់បន្ថែមនៅលើគេហទំព័រ៖ ph.lacounty.gov/measles។